# ការសម្ភាសន៍របស់អ្នកមីង យុត សួន

កៈ អ្នកសម្ភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសម្ភាសន៍ យុត សួន

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់អ្នកមីង យុត សួន

សង្ខេបៈ អ្នកមីង យុត សួន គាត់មានអាយុហុកសិបប្រាំមួយឆ្នាំ គាត់បានកើតនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ហើយគាត់ជាកូនទីពីរនៅក្នុងក្រុមគ្រួសារដែលមានបងប្អូនចំនួនបួននាក់ ហើយគាត់បានរៀបការនៅអាយុដប់ប្រាំបីឆ្នាំ ហើយនៅជំនាន់ពលពតគាត់បានបែកពីប្ដីរបស់គាត់ដោយសារប្ដីរបស់គាត់បានយកប្រពន្ធមួយទៀត ហើយគាត់បានរស់ជាមួយកូនស្រីទាំងបីនាក់របស់គាត់ដោយគ្មានប្ដី។ នៅក្នុងជីវិតរបស់គាត់មានការលំបាកច្រើន ហើយមិនសូវមានពេលដែលសប្បាយច្រើនទេ គាត់បានព្យាយាមរកពេលដែលសប្បាយដែរដើម្បីបំភ្លេចនូវការលំបាករបស់គាត់តែពេលសប្បាយបានបន្តិចគាត់ក៏នឹងឃើញទុក្ខលំបាករបស់គាត់ធ្វើអោយមិនមានពេលដែលសប្បាយច្រើនដូចគេនោះទេ។ធ្វើឡើងនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៤ ខែ០៤ ឆ្នាំ២០១៨។

កៈ អញ្ចឹង ជំរាបសួរអ្នកមីង ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ប្រជាជនកម្ពុជា ដែលធ្វើឡើយដោយសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ នៅសហរដ្ឋអាមេរិច។ ដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរទុកអោយកូនចៅជំនាន់ ក្រោយរបស់ពួកគាត់ ស្គាល់ពីប្រវត្តិរបស់ជីដូនជីតាហើយនឹងឪពុកម្ដាយ។ ហើយការសម្ភាសន៍នេះ យើងធ្វើនៅថ្ងៃទី២៤ ខែ០៤ ឆ្នាំ២០១៨ ហើយការសម្ភាសន៍នេះយើងធ្វើនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយសំរាប់ការសម្ភាសន៍នេះយើងនឹងថតសំលេង និងថតរូបភាពរបស់អ្នកមីង ហើយផ្ញើរទៅសកលវិទ្យាល័យ ដើម្បីពួកគេអាចយកទៅដាក់នៅលើ វេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង តើអ្នកមីងយល់ព្រមអោយយើងយកសំលេង ហើយរូបថតរបស់អ្នកមីង យកទៅដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យទេអ្នកមីង?

ខៈ មានអីយកចុះក្មួយមីងមិនថាអីទេ។

ក៖ អរគុណច្រើនអ្នកមីងដែលអោយយើងសំលេង និងរូបថតមីងដាក់លើវេបសាយរបស់សាកល វិទ្យាល័យ។ ហើយអញ្ជឹង ជាដំបូងខ្ញុំសុំសួរអ្នកមីងថា តើអ្នកមីងមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះ យុត សួន។

ក៖ ឈ្មោះយុត សួន! ហើយអញ្ជឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ អត់មានទេ មានតែយុត សួននឹងតែម្តង។

ក៖ ហើយអញ្ជឹង កាលនៅក្មេងៗ តើគេហៅអ្នកមីងឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ កាលនៅក្មេងៗគេហៅ សួន។

ក៖ ហើយអញ្ជឹង សំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានអាយុប៉ុន្មានហើយ អ្នកមីង?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុហុកសិបប្រាំមួយឆ្នាំហើយ។

ក៖ ហុកសិបប្រាំមួយឆ្នាំហើយន៎ មីងន៎! ហើយអញ្ជឹង តើអ្នកមីងចាំទេថា អ្នកមីងបានកើតនៅឆ្នាំណា ដែរអ្នកមីង?

ខ៖ មីងអត់ដឹងកើតឆ្នាំណាទេ តែគ្រាន់តែដឹងថាមានអាយុហុកសិបប្រាំមួយ។

ក៖ អញ្ជឹង អ្នកមីងចាំតែថាមីងមានអាយុហុកសិបប្រាំមួយឆ្នាំ។ អញ្ជឹងអ្នកមីងបានកើតប្រហែលជា ឆ្នាំមួយពាន់ប្រាំបួនរយហាសិបពីរ។ ហើយអញ្ជឹង សំរាប់ឆ្នាំខ្មែរយើង ជូត ឆ្លូវ ខាល ថោះ តើអ្នកមីង ចាំទេថា អ្នកមីងបានកើតក្នុងឆ្នាំណាដែរ?

ខ៖ ខ្ញុំកើតឆ្នាំម្សាញ់។

ក៖ អូ! អ្នកមីងកើតឆ្នាំម្សាញ់! ហើយអញ្ជឹង សំរាប់អ្នកមីង តើអ្នកមីងបានកើតនៅក្នុងខេត្តណាដែរ អ្នកមីង?

ខ៖ ខ្ញុំកើតនៅនឹង គេហៅខេត្តកំពង់ចាម តែឥឡូវគេដូរឈ្មោះទៅជាខេត្តត្បូងឃ្មុំ។

ក៖ អូ! អញ្ជឹងពេលដែលអ្នកមីងកើតនឹងឈ្មោះខេត្តកំពង់ចាម តែឥឡូវដូរឈ្មោះទៅជាត្បូងឃ្មុំ។ ហើយអញ្ជឹង តើអ្នកមីងចាំឈ្មោះ ភូមិ ឃុំ ស្រុក ដែលអ្នកមីងបានកើតទេ?

ខ៖ នៅចាំតើ កាលកើតនឹងនៅភូមិផ្អត់ដំរី ឃុំដំរិល ស្រុកអូររាំងឪ។

កៈ អញ្ចឹងអ្នកមីងកើតនៅភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ។ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ អ្នកមីង?

ខៈ បងប្អូនមីងមានបួននាក់។

កៈ មីងមានបងប្អូនបួននាក់។ ហើយចុះមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារ អ្នកមីង?

ខៈ ខ្ញុំជាកូនទីពីរ។

កៈ អូ! អ្នកមីងជាកូនទីពីរបន្ទាប់បង។ ហើយអញ្ចឹង សំរាប់បងប្អូនរបស់អ្នកមីង មានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ ស្រីបីនាក់ ហើយប្រុសម្នាក់។

កៈ ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនអ្នកមីងទាំងបួននាក់បានទេ?

ខៈ បានតើ បងប្រុសឈ្មោះខេង ហើយមកបន្ទាប់មកទៀតខ្ញុំ
ហើយបន្ទាប់ពីខ្ញុំប្អូនស្រីឈ្មោះស៊ុម ហើយមកមួយទៀតឈ្មោះសឿន។

កៈ ហើយអញ្ចឹង កាលដែលអ្នកមីងនៅក្មេងៗ
តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនទាំងអស់នឹង អ្នកមីង?

ខៈ កាលនៅក្មេងៗមីងមានធ្វើអីទេមើលតែគោ មើលតែក្របីនឹង
គ្មានធ្វើអីទេលេងតែជាមួយបងៗ។

កៈ នឹងហើយ លេងជាមួយគ្នាអញ្ចឹងទៅន៎អ្នកមីង។ ហើយអញ្ចឹង អ្នកមីងមានធ្លាប់ទៅរៀន ជាមួយគ្នាទេអ្នកមីង?

ខៈ មីងអត់បានរៀនទេ ជាប់តែមើលក្របី មើលគោ ម៉ែឪគ្មានលុយអោយទៅរៀនទេ។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង
តើពួកគាត់រស់នៅកន្លែងណាដែរអ្នកមីង?

ខៈ បងខ្ញុំនៅភូមិសមខ្មែរ ហើយខ្ញុំនៅនឹង ហើយប្អូនស្រីមួយទៀតនៅភូមិព្រៃបាំង
ហើយប្អូនមួយ ទៀតនៅភូមិនឹងដែរ។

កៈ អូ! អញ្ចឹងនៅភូមិនឹងនៅពីរនាក់ន៎អ្នកមីង។ ហើយសំរាប់សព្វថ្ងៃនេះ
តើពួកគាត់ទាំងអស់គ្នានឹង ប្រកបមុខរបរអ្វីចិញ្ចឹមជីវិតដែរអ្នកមីង?

ខ៖ ធ្វើស្រែ ធ្វើស្រែតែម្ដង សុទ្ធតែធ្វើស្រែទាំងអស់គ្នាតែម្ដង។

ក៖ អូ! ធ្វើស្រែទាំងអស់គ្នាតែម្ដង។ ហើយអញ្ចឹង សំរាប់អ្នកមីង
តើឪពុករបស់អ្នកមីងមានឈ្មោះអ្វី ដែរអ្នកមីង?

ខ៖ ខ្ញុំរបស់ខ្ញុំគាត់ឈ្មោះ យុត ញ៉ូង។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះឪពុកអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ គាត់ស្លាប់បាត់ហើយ កាលដែលគាត់ស្លាប់នឹងគាត់មានអាយុប៉ែតសិបប្រាំឆ្នាំ។

ក៖ អូ! គាត់ស្លាប់អាយុប៉ែតសិបប្រាំឆ្នាំ។ ហើយអញ្ចឹង
តើគាត់ស្លាប់អស់រយៈពេលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ មិនដឹងប៉ុន្មានឆ្នាំទេ ព្រោះអីយូរដែលហើយនឹង។

ក៖ អញ្ចឹងគាត់ស្លាប់តាំងពីមុនសម័យពលពត ឬមួយក្រោយសម័យពលពត?

ខ៖ គាត់ស្លាប់ក្រោយសម័យពលពតទេ។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីង គាត់កើតឆ្នាំអីដែរអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់កើតឆ្នាំថោះ។

ក៖ គាត់កើតឆ្នាំថោះ។ ហើយអញ្ចឹង ពេលដែលឪពុករបស់មីងបានស្លាប់នឹង
ពេលនោះអ្នកមីង មានអាយុប្រហែលប៉ុន្មានឆ្នាំដែរ អ្នកមីង?

ខ៖ មិនដឹងជាប៉ុន្មានដែលនឹង បើមិនដែលនឹងបានគិតផង។

ក៖ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់បានកើតនៅកន្លែងណាដែរអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់កើតនៅស្រុកនឹងដែរ។

ក៖ ហើយចុះ តើម្ដាយរបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ម្ដាយរបស់ខ្ញុំគាត់ឈ្មោះយាយ នុន។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះម្ដាយរបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយ
អ្នកមីង?

ខ៖ គាត់នឹងកាលស្លាប់នឹងអាយុប៉ែតសិបបីឆ្នាំ។

ក៖ អូ! ម្ដាយរបស់អ្នកមីងគាត់បានស្លាប់នៅអាយុប៉ែតសិបបីឆ្នាំ។

ខ៖ ម្ដាយរបស់ខ្ញុំស្លាប់អាយុប៉ែតសិបបីឆ្នាំ ហើយឪពុកខ្ញុំស្លាប់អាយុប៉ែតសិបប្រាំឆ្នាំ។

ក៖ ហើយម្ដាយរបស់អ្នកមីង គាត់បានស្លាប់អស់រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ម្ដាយរបស់ខ្ញុំគាត់បានស្លាប់ឆ្នាំទៅមួយ(ពីរឆ្នាំហើយ)។

ក៖ ហើយអញ្ចឹង អ្នកមីងអត់ចាំថាម្ដាយរបស់អ្នកមីងបានស្លាប់នៅឆ្នាំណាទេ?

ខ៖ អត់ចាំទេ។

ក៖ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ្នកមីងគាត់កើតឆ្នាំអ្វីដែរអ្នកមីង?

ខ៖ ម្ដាយរបស់ខ្ញុំគាត់កើតឆ្នាំមមី។

ក៖ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់អ្នកមីង កាលដែលពួកគាត់នៅរស់
តើពួកគាត់ប្រកប មុខរបរអ្វីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខ៖ ធ្វើស្រែ ធ្វើស្រែទាំងអស់គ្នា។

ក៖ ហើយអញ្ចឹង ក្រៅពីធ្វើស្រែ
គាត់អត់មានប្រកបមុខរបរអ្វីផ្សេងដូចជាឡើងត្នោតឡើងអីនឹង?

ខ៖ អត់ទេ ក្រៅពីធ្វើស្រែ មើលក្របីតែម្ដង។

ក៖ ធ្វើស្រែហើយ មើលក្របីតែម្ដង។

ខ៖ ក្រៅពីធ្វើស្រែហើយ មើលក្របីតែម្ដង។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីង គាត់ជាមនុស្សបែបណាដែរ សំរាប់ចរិតលក្ខណៈ
របស់គាត់?

ខ៖ ចរិតរបស់ឪពុកខ្ញុំស្លូតណាស់ ស្លូតតែម្ដង គាត់មានដែលទៅធ្វើបាបពីណាគេទេ
ស្លូតណាស់។

ក៖ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ្នកមីង តើគាត់មានចរិតលក្ខណៈដូចម្ដេចដែរ?

ខ៖ ម្ដាយរបស់ខ្ញុំក៏អញ្ចឹងដែរ ដូចគ្នា ស្លូតដូចគ្នា មិនដែលទៅមាត់អោយពីណា
ឬទៅឈ្លោះជាមួយ ពីណា អត់ដែលមានសោះ
ត្រូវគ្នាជាមួយគេទាំងអស់អ្នកស្រុកអ្នកភូមិ។

ក៖ ហើយអញ្ចឹង អ្នកមីងមាននៅចាំសាច់រឿងពីខ្សែជីវិតរបស់ឪពុកម្ដាយរបស់អ្នកមីងទេ?

ខ៖ ម្ដាយឪពុកខ្ញុំកំសត់ណា ក្រណាស់ធ្វើស្រែពិបាកមួយរដូវ ធ្វើអស់ស្រូវតែមួយកូនល្អីទេ ប្រពន្ធ កូនខ្ញុំភ្លោះទៀត ហើយពឹងអីវាមិនក្រ។

ក៖ ហើយអញ្ចឹង
តើឪពុកម្ដាយរបស់អ្នកមីងគាត់ធ្លាប់ប្រាប់អ្នកមីងអំពីជីវិតរបស់ពួកគាត់កាលគាត់
នៅក្មេងៗទេ អ្នកមីង?

ខ៖ គាត់និយាយថា ម្ដាយពិបាកណាស់កូនអើយ ក្រណាស់
រកស៊ីបានមកយកទៅសងតែគេ ធ្វើស្រូវ មិនបានហូបដល់ឆ្នាំវិញទេ
ហូបបានតែពាក់កណ្ដាលឆ្នាំ ទៅយកស្រូវចិនមកហូបហើយ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខ៖ អូ! អត់ចាំទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងទេ?

ខ៖ ឈ្មោះយាយគឹម។

ក៖ ហើយចុះតា តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ តាភ្លេចទៀតហើយ ភ្លេចឈ្មោះតាហើយ។

ក៖ អញ្ចឹងចាំតែឈ្មោះយាយគឹង ហើយតាអត់ចាំទេ។ ហើយអញ្ចឹងអ្នកមីងមាននៅចាំទេថា គាត់កើតនៅឆ្នាំណាដែរ?

ខ៖ អូ! អត់ចាំទេ។

ក៖ ហើយអញ្ចឹង សំរាប់ក្រុមគ្រួសារអ្នកមីង
រស់នៅខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយមីង?

ខ៖ នៅយូរហើយ តាំងពីគាត់កើតមករស់នៅក្នុងស្រុកនឹងរហូត
នៅតែស្រុកនឹងមិនដែលចេញទៅ ណាទេ។

ក៖ នៅនឹងរហូតន៎អ្នកមីងន៎! ហើយអញ្ចឹង អ្នកមីងមានសាច់ញាត្តិដទៃ
ដែលរស់នៅក្រៅប្រទេស ខ្មែរយើងទេ អ្នកមីង?

ខ៖ គ្មានទេ មានតែនៅស្រុកយើងនឹងទេ។

ក៖ ហើយអញ្ចឹង សំរាប់ស្វាមីរបស់អ្នកមីង តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ប្ដីរបស់ខ្ញុំគាត់ឈ្មោះវាញ ភេន។

ក៖ វាញ ភេន! ហើយអញ្ចឹង អ្នកមីងមាននៅចាំទេថា
អ្នកមីងបានរៀបការជាមួយគាត់នៅពេលណាទេអ្នកមីង?

ខ៖ អូ! អត់ដឹងទេ ភ្លេីទាំងអស់តែម្ដង។

ក៖ ហើយអញ្ចឹង អ្នកមីងមានចាំទេថា ពេលដែលអ្នកមីងបានរៀបការជាមួយគាត់នឹង
អ្នកមីងមាន អាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ពេលខ្ញុំរៀបការជាមួយគាត់ ខ្ញុំមានអាយុដប់ប្រាំបីឆ្នាំ។

ក៖ អូ! ពេលដែលអ្នកមីងមានអាយុដប់ប្រាំបីឆ្នាំអ្នកមីងបានរៀបការជាមួយលោកពូ។
ហើយមក ដល់សព្វថ្ងៃនេះ
តើអ្នកមីងបានរៀបការជាមួយប្ដីរបស់អ្នកមីងបានប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ការដឹងបានប៉ុន្មានឆ្នាំដែរទេ យូរដែរហើយតាំងពីខ្ញុំអាយុដប់ប្រាំបីឆ្នាំមកម្លេះ
រហូតមកដល់យើង បែកគ្នាជំនាន់អាពត។

ក៖ អូ! អញ្ចឹងអ្នកមីងបែកគ្នាជាមួយលោកពូនៅជំនាន់អាពត។ ហើយអញ្ចឹង
បែកគ្នានឹងដោយសារ អាពតគេអ្នកបំបែក ឬមួយក៏គាត់បានស្លាប់?

ខ៖ បែកគ្នាដោយសារតែគេមានប្រពន្ធទៀត។

ក៖ អូ! អញ្ចឹងគាត់យកប្រពន្ធថ្មីមួយផ្សេងទៀត។ ហើយអញ្ចឹង
អ្នកមីងរៀបការហើយបែកគ្នានឹង តើអ្នកមីងរៀបការបានប៉ុន្មានឆ្នាំ បានអ្នកមីងបែកគ្នា?

ខ៖ បានយូរតើ អាយុប៉ុន្មានហើយទេនេះ អាយុសែសិបក៏មិនដឹង អាយុសាមជាងក៏មិនដឹង
វាពិបាក ពេកមិនបានគិតទេរឿងអាយុបែកគ្នាប៉ុនណះប៉ុនណះ។

ក៖ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុកម្ដាយ
ឬមួយរៀបចំឡើងដោយ ខ្លួនឯង អ្នកមីង?

ខ៖ ឪពុកម្ដាយ ជឿលើម៉ែឪគាត់ជាអ្នករៀបចំអោយ។

ក៖ ហើយអញ្ចឹង ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង មានដូចជាថ្លៃជំនួនទេអ្នកមីង?

ខ៖ មានជំនួន មានផ្លែឈើផ្លែអី លុយកាក់អីបន្តិចបន្តួចដែរណា មិនមែនគ្មានទេ មាន។

ក៖ ហើយថ្លៃជំនួននឹង ប្រហែលជាប៉ុន្មានដែរអ្នកមីង?

ខ៖ ជំនួននឹងមាសគេបីជី ហើយនឹងផ្លែឈើសព្វគ្រប់។

ក៖ អូ! មានមាសបីជីហើយមានផ្លែឈើសព្វមុខទៀត! ហើយអញ្ចឹង
សំរាប់ចំណងអាពាហ៍ពិពាហ៍ របស់អ្នកមីងមានកូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ មានកូនបីនាក់។

ក៖ ហើយសំរាប់កូនរបស់អ្នកមីង មានកូនប្រុសប៉ុន្មាននាក់ ហើយកូនស្រីប៉ុន្មាននាក់?

ខ៖ កូនមីងសុទ្ធតែស្រីទាំងអស់។

ក៖ អូ! សុទ្ធតែស្រីទាំងអស់។ ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះកូនទាំងបីនាក់របស់ អ្នកមីងបានទេ?

ខ៖ បានតើ កូនដំបូងនឹងឈ្មោះម៉ៃ ហើយកូនកណ្តាលឈ្មោះរុំ
ហើយកូនក្រោយគេនឹងឈ្មោះរ៉េន។

ក៖ ហើយសំរាប់សព្វថ្ងៃនេះ កូនរបស់អ្នកមីងទាំងអស់រស់នៅកន្លែងណាដែរអ្នកមីង?

ខ៖ កូនខ្ញុំទីពីរនឹងនៅរកស៊ីនៅថៃ ហើយកូនបងគេបង្អស់នឹងនៅភូមិយៀក
ហើយកូនខ្ញុំពៅគេនឹង រស់នៅភូមិនឹង។

ក៖ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ កូនអ្នកមីងទាំងបីនាក់នឹង
គាត់ប្រកបមុខរបរអ្វីដែរអ្នកមីង?

ខ៖ ធ្វើស្រែ ផុតពីធ្វើស្រែទៅ ដើរស៊ីឈ្នួលគេ ទាំងអស់គ្នា។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងចេះអាន និងសរសេរអក្សរខ្មែរទេអ្នកមីង?

ខ៖ មីងអត់ចេះទេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីងចេះនិយាយភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរទេ?

ខ៖ មិនចេះទេ។

ក៖ ហើយអញ្ចឹង តើមីងមានមិត្តភក្តិជិតស្និទដែលធំធាត់មកជាមួយគ្នាទេអ្នកមីង?

ខ៖ មិត្តជិតស្និតគ្មានទេ មានតែរាប់អានធម្មតាៗ។

ក៖ ហើយតើពួកគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ មានតែអ្នកស្រុកអីនឹងណា អ្នកស្រុកនឹងតើ។

ក៖ អូ! អ្នកស្រុកជាមួយគ្នានឹង។ ហើយអញ្ចឹង កាលពីក្មេងៗ
អ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយមិត្តភក្តិ ទាំងអស់នឹង អ្នកមីង?

ខ៖ អូ! ពីក្មេងៗលេងមើលអញ្ចឹងទៅ លេងប៉េង លេងវាយកូនប៉េង។

ក៖ មានអនុស្សាវរីយ៍ល្អណាស់កាលពីនៅក្មេងនឹងអ្នកមីង។

ខ៖ សុទ្ធតែស្រីៗទេលេងនឹង អត់មានប្រុសលេងជាមួយទេ។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះអ្នកមីងមានធ្វើស្រែចំការទេអ្នកមីង?

ខ៖ ធ្វើតែស្រែទេក្មួយអើយ ធ្វើតែស្រែទេគ្មានធ្វើអីទេ រួចតែពីស្រែនឹង ដើរស៊ីឈ្នួលគេ។

ក៖ អ្នកមីងស៊ីឈ្នួលគេ ធ្វើអីគេខ្លះទៅអ្នកមីង?

ខ៖ មើលអាវៀនទៅស៊ីឈ្នួលចងដែកអោយគេ
ហើយប្រពន្ធទៅស៊ីឈ្នួលបេះម្រេចអោយគេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងគិតថាជីវិតរបស់អ្នកមីង
តាំងពីក្មេងរហូតមកដល់ពេលនេះមានការផ្លាស់ប្តូរទេអ្នកមីង?

ខ៖ វាផ្លាស់ប្តូរហើយ វាពិបាកណាស់ ពិបាកមែនទែនណាក្មួយ
មីងមិនបានស្រួលអីនឹងគេទេរាល់ថ្ងៃ នេះ ពិបាកព្រួយចិត្តនឹងកូននឹងចៅសព្វគ្រប់
ជំពាក់គេសងគេមិនទាន់រួច ជំពាក់គេនៅច្រើន។

ក៖ ហើយអញ្ចឹង សំរាប់ម្ហូបវិញ តើអ្នកមីងចូលចិត្តហូបម្ហូបអ្វីជាងគេអ្នកមីង?

ខ៖ មីងចូលចិត្តហូបសម្លម្ជូរ ហើយស្ងោរ។

ក៖ ហើយអញ្ចឹង សំរាប់ល្បែងប្រជាប្រិយខ្មែរយើង
តើអ្នកមីងចូលចិត្តលេងល្បែងអ្វីជាងគេតាំងពីក្មេងរហូតមកដល់ពេលនេះ?

ខ៖ តាំងពីក្មេងរហូតមកដល់ឥឡូវមានតែរាំ ចូលចិត្តរាំវង់ រាំក្បាច់ សារាវ៉ាន់ ហើយមកឥឡូវនឹង ចូលចិត្តលេងទាញព្រ័ត្រតែម្តង ទាញបានតែពីបីដងទៅ នាំគ្នារាំតែម្តង។

ក៖ អូ! អ្នកមីងលេងទាញព្រ័ត្រនឹងអ្នកមីងលេងនៅវត្តយើងនឹងហ៎?

ខ៖ នឹងហើយលេងនៅវត្តដំរិលយើងនឹង។

ក៖ ហើយសំរាប់បទចម្រៀងវិញ តើអ្នកមីងមានបទចម្រៀងណាដែលអ្នកមីងចូលចិត្ត ហើយរៀនច្រៀងតាម តាំងពីក្មេងមក?

ខ៖ មីងមិនដែលច្រៀងតាមទេ គ្រាន់តែធ្លាប់ស្តាប់លឺគេច្រៀងមក ដឹងថាបទណាពិរោះក៏ពិរោះទៅ ហើយបទណាមិនពិរោះ ក៏មិនពិរោះទៅ។

ក៖ ហើយអញ្ចឹង នៅក្នុងក្រុមគ្រួសាររបស់អ្នកមីង មាននរណាម្នាក់ដែលចេះរៀនឧបករណ៍ភ្លេងដែរឬទេ អ្នកមីង?

ខ៖ អត់មាននៅក្នុងគ្រួសារកូនចៅខ្ញុំ គ្មានអ្នកណាចេះលេងទេ។

ក៖ ហើយអញ្ចឹង តើផ្ទះរបស់អ្នកមីងមានលក្ខណៈយ៉ាងដូចម្តេចដែរ តាំងពីក្មេងរហូតមកដល់ពេលនេះ?

ខ៖ ផ្ទះខ្ញុំកាលនៅជាមួយម្តាយផ្ទះតូចទេ ទើបមកកូននឹងគេធ្វើបានផ្ទះធំនៅនឹង ទល់ដល់កូននឹងវា ទៅក៏អស់រលីងទៀតទៅ ហើយជំពាក់គេទៀត។

ក៖ ហើយអញ្ចឹង កាលពីក្មេងនឹងផ្ទះនឹងមានលក្ខណៈដូចម្តេចដែរអ្នកមីង ផ្ទះទាបឬមួយផ្ទះខ្ពស់?

ខ៖ ផ្ទះកាំជណ្តើរប្រាំកាំ ផុតពីប្រាំមកផ្ទះកាំជណ្តើរបីកាំ ហើយផុតពីផ្ទះកាំជណ្តើរបីកាំ មកផ្ទះនឹងតែម្តង។

ក៖ ហើយសំរាប់ផ្ទះនឹង អ្នកមីងធ្វើដោយខ្លួនឯង ឬមួយអ្នកមីងជួលគេអោយធ្វើអោយ?

ខ៖ ផ្ទះមួយទិញគេ ហើយផ្ទះមួយទៀតជាផ្ទះរបស់ម្តាយទេ កាលនោះយើងនៅជាមួយម្តាយ។

ក៖ ហើយអញ្ចឹង ផ្ទះដែលអ្នកមីងនៅជាមួយម្តាយនឹង ធ្វើឡើងដោយសំភារៈអ្វីខ្លះអ្នកមីង?

ខ៖ ដើមត្នោត កូនឈើខ្លះទៅ ប្រក់ស្លឹកត្នោត ប្រក់ចំបើង ពេលដែលយើងច្រូតមក យើងយកមក ជជុះប៉ែនយកមកក្រងប្រក់ទៅ ធ្វើម៉េចបើយើងអត់។

ក៖ ហើយអញ្ចឹង នរណាគេដែលជាអ្នកបង្រៀនអោយធ្វើផ្ទះមួយនឹង អ្នកមីង?

ខ៖ ផ្ទះនឹងគាត់ទៅរកបងប្អូនគាត់អោយមកជួយធ្វើ។

ក៖ ហើយអញ្ចឹង តើមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេ ដូចជាវេញវល្លិ៍ផ្តៅ ឬក៏ជំនាញធ្វើ ស្ករត្នោត ឬក៏ត្បាញហូល ត្បាញផាមួង ក្រមាអីទេមីង?

ខ៖ អត់មានទេ មិនដែលធ្វើទេ។

ក៖ ហើយអញ្ចឹង អ្នកមីងធ្លាប់មានពេលដែលលំបាកជាងគេនៅក្នុងជីវិតទេអ្នកមីង?

ខ៖ មានក្មួយអើយ លំបាកណាស់នៅក្នុងជីវិតនេះ
មានពេលដែលលំបាកណាស់រហូតចង់អោយ ស្លាប់ភ្លេមក៏មានដែរ
នឹងពេលដែលលំបាកពេក។

ក៖ ហើយអញ្ចឹង ពេលដែលអ្នកមីងបានជួបពេលដែលលំបាកចឹង
តើអ្នកមីងបានធ្វើអ្វីខ្លះដើម្បីយក ឈ្នះលើពេលដែលលំបាកនឹង អ្នកមីង?

ខ៖ មីងចេះទ្រាំហើយអត់ធ្មត់ទៅ យូរទៅវាបានសុខជាមួយគ្នាហើយ
ដល់ពេលដែលយើងមិនទ្រាំ មិនអត់ធ្មត់នឹង វាមានតែខូចខាត ហើយនឹងព្រាត់គ្នា។

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានពេលវេលា ឬមួយបទពិសោធន៍ដែលសប្បាយៗទេ ដូចជាការរៀបអាពាហ៍ពិពាហ៍កូនចៅ ឬមួយបុណ្យទាននៅនឹងផ្ទះនឹង?

ខ៖ មាន ប៉ុន្តែយើងធ្វើបានបន្តិចបន្តួចវាមិនបានធំដំដូចគេទេ បងប្អូនក៏ធ្វើបុណ្យទៅ
រៀបការក៏រៀបការទៅ ទៅសប្បាយជាមួយនឹងគេទៅ
ហើយដល់ផុតពីនឹងទៅនឹកឃើញខ្លួនឯងទៀតហើយថា ពិបាក។

ក៖ ហើយអញ្ចឹង បើសិនអ្នកមីងចង់ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយ
តើអ្នកមីងចង់ផ្តាំផ្ញើរអោយពួកគាត់ធ្វើអ្វីខ្លះអ្នកមីង?

ខ៖ អោយកូនចៅប្រឹងធ្វើតែល្អ ប្រឹងខំរក ប្រឹងខំធ្វើអោយបាន បើយើងមិនខំមិនប្រឹង យើងមិនបានទេ។

ក៖ ហើយអញ្ចឹង បើសិនអ្នកមីងចង់អោយគាត់ជៀសវាង
តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរអ្នកមីង?

ខៈ អោយជៀសវាងពីគ្រោះថា្នក់ អោយផុតពីទុកកុំអោយមានគ្រោះថ្នាក់ អោយចេះតែសុខរហូត។

កៈ ហើយអញ្ចឹងសំរាប់បញ្ហាសង្គមដូចជា គ្រឿងញៀន គ្រឿងស្រវឹង តើអ្នកមីងចង់ផ្តាំផ្ញើរអោយពួកគាត់អ្វីខ្លះដែរ អ្នកមីង?

ខៈ មីងផ្តាំណាស់អារឿងគ្រឿងញៀននឹងកុំអោយផឹកកុំអោយជក់ ផ្តាំនោះមហាផ្តាំហើយកុំអោយ ប្រព្រឹត្តអោយសោះ។

កៈ ផ្តាំសឹងរាល់ថ្ងៃតែម្តងណាំមីងណាំ!

ខៈ ដូចចៅមួយនៅថៃក៏អញ្ចឹងដែរ ផ្តាំរាល់ថ្ងៃថា ចៅអើយចៅ កុំជក់កុំប្រព្រឹត្តរឿងអាក្រក់ ធ្វើតែល្អទៅយើងបានល្អហើយ។

កៈ ហើយចុងក្រោយនេះ ខ្ញុំសូមអរគុណអ្នកមីង ដែលអ្នកមីងបានចំណាយពេលវេលាដើម្បីអោយខ្ញុំ សម្ភាសន៍ពីខ្សែជីវិតរបស់អ្នកមីង ដឹងពីពេលវេលាដែលអ្នកមីងលំបាក ហើយនឹងពេលវេលាដែលអ្នកមីងសប្បាយ ហើយចុងក្រោយនេះខ្ញុំសូមជូនពរអ្នកមីងអោយមានសុខភាពល្អ មានកំលាំង មាំមួន ហើយថាកូនចៅរបស់អ្នកមីងមានសុខភាព មានប្រាជ្ញាវាងវៃ ដើម្បីឈ្នះលើឧបសគ្គ ជាពិសេសដើម្បីអាចជោគជ័យលើមុខរបររកស៊ីរបស់ពួកគាត់ ហើយថាពួកគាត់ជៀសផុតពីគ្រោះថ្នាក់ទាំងឡាយទាំងពួង។ ហើយចុងក្រោយសូមអរគុណអ្នកមីងច្រើនហើយមីង!!!!!